**REDRESS**
seeking reparation for torture survivors

# សង្ខេបព័ត៌មាន:

## “សង្គមស៊ីវិលគិតគូរអំពីសំណងសំរាប់ជនរងគ្រោះនៃរបបខ្មែរក្រហម”

*ភ្នំពេញថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០០៩*

កាលពីខែវិច្ឆិកា ឆ្នាំ២០០៨ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) និងអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរៀបចំនូវសន្និសីទអន្តរជាតិជាលើកដំបូងគេ ដែលបានជជែកពិភាក្សាយ៉ាងទូលំទូលាយអំពីសំណង និង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ មួយឆ្នាំបន្ទាប់មកទៀត គណៈកម្មាធិការប្រព្រឹត្តិកម្ម បានរួមសហការគ្នាជាមួយនឹងអង្គការ Redress បានរៀបចំឱ្យមានសិក្ខាសាលាមួយទៀត កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅទីក្រុងភ្នំពេញ និងបានបញ្ចេញនូវឯកសារពិគ្រោះពិភាក្សាមួយ ដើម្បីជាការគិតគូរបន្ថែមទៀតស្របតាមស្ថានភាពដែលបានវិវត្តន៏ប្រែប្រួល និង ដើម្បីលើកទឹកចិត្តឱ្យមានការជជែកពិភាក្សាបន្ថែមទៀត ពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅជំហានបន្ទាប់មកទៀតនេះ ក្នុងគោលបំណងដើម្បីធ្វើឱ្យទស្សនៈវិស័យ និងការប្រមើលមើលអំពី សំណងសំរាប់ជនរងគ្រោះ នៃរបបខ្មែរក្រហម អាចអនុវត្តន៏ទៅបាន ជាក់ស្តែងយ៉ាងពិតប្រាកដ។

ចៅក្រម នៃ អង្គជំនុំជម្រះវិសាមញ្ញ បានគិតគូរយ៉ាងច្បាស់លាស់ហើយអំពី អាណត្តិនៃសំណងតាមរយៈការអនុម័តនូវវិធានផ្ទៃក្នុង ដែល “*អនុញ្ញាតឱ្យជនរងគ្រោះស្វែងរកសំណងសមូហភាព និងសំណងផ្លូវចិត្ត*”។ ការពិត អង្គជំនុំជម្រះវិសាមញ្ញនេះ ដើរតួនាទីយ៉ាងសំខាន់ជាកត្តាលីករមួយនៅក្នុងដំណើរការសំណង ទោះបីជាមានភាគីពាក់ព័ន្ធផ្សេងៗដទៃទៀតក្តី វាក៏ត្រូវការចាំបាច់ឱ្យមានការចូលរួមពីសំណាក់: រាជរដ្ឋាភិបាល, ជនរងគ្រោះ និង សមាគមជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកចូលរួមវិភាគទាន ដទៃផ្សេងទៀតផងដែរ។

នៅក្នុងកិច្ចប្រជុំពេញអង្គចៅក្រម កាលពីខែកញ្ញា ឆ្នាំ២០០៩ កន្លងទៅនេះ ចៅក្រម នៃអង្គជំនុំជម្រះវិសាមញ្ញ បានប្រកាសថា គេនឹងអាចណែនាំអំពីវិសោធនកម្មសំខាន់ៗជាមូលដ្ឋានមួយចំនួនទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធីរបស់សាលាក្តីនេះ។ ការផ្លាស់ប្តូរនោះ ទំនងជានឹងអាចប៉ះពាល់ផងដែរនូវវិធានផ្ទៃក្នុងបច្ចុប្បន្នដែលកំពុងតែមានចែងអំពីបញ្ហាសំណង។ គណៈកម្មាធិការប្រព្រឹត្តិកម្ម និងអង្គការ Redress សូមរំលឹកថា តុលាការនេះ គឺជាតួអង្គជានិមិត្តរូបគន្លឹះមួយ ដែលមាននៅទីនេះ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងវាក៏ចាំបាច់ឱ្យតុលាការនេះ ធ្វើការបកស្រាយនូវគ្រប់ទិដ្ឋភាពទាំងអស់នៃអាណត្តិការងាររបស់ខ្លួន (រួមទាំងបញ្ហាសំណងនេះផង)។ ជនរងគ្រោះ គឺជាគន្លឹះឈានទៅរកការបង្កើតឱ្យមានមរតកដ៏សំខាន់សំរាប់ប្រទេសកម្ពុជា ផងដែរ។

ជាក់ស្តែង អនុសាសន៍សំខាន់ៗដែលបានដាក់ចេញនៅក្នុងឯកសារពិគ្រោះពិភាក្សានេះមានដូចខាងក្រោមៈ

១- នៅជិតចុងបញ្ចប់នៃសំណុំរឿង០០១នេះ គេត្រូវការឱ្យចៅក្រមទាំងអស់ រៀបចំនូវដីកាបង្គាប់សំណង ដោយបញ្ជាក់ឱ្យបានកាន់តែច្បាស់លាស់នូវអាណត្តិរបស់គេ ក្នុងការចេញនូវ *សំណងជាសមូហភាព និង សំណងផ្លូវចិត្ត* ហើយចៅក្រម ក៏ត្រូវបកស្រាយបន្ថែមទៀតអំពី ការអនុវត្តន៍សំណងជាក់ស្តែងរបៀបណាផងដែរ ។

២- អង្គជំនុំជម្រះនេះ គួរតែពិភាក្សាឱ្យបានទូលំទូលាយ និង ទាក់ទាញឱ្យមានការចូលរួមរបស់ជនរងគ្រោះនៅគ្រប់តំណាក់កាលទាំងអស់ នៃ ដំណើរការគិតគូរអំពីសំណងនេះ ។

៣- សំណងបែបណាក៏ដោយ ទោះបីជាសំណងភាគច្រើនដែលមានលក្ខណៈជានិមិត្តរូប ក៏នៅតែត្រូវការឱ្យមានថវិកា ដែរ ។ ដូចនេះ តុលាការត្រូវការគិតគូរអំពីបញ្ហានេះថែមទៀត គឺថា តុលាកាមានភារកិច្ចធានាថា សេចក្តីសំរេចអំពីសំណង ត្រូវតែមានភាពជាក់ស្តែង និងមានប្រសិទ្ធិភាព និងអាចអនុវត្តបាន ។ ដូចនេះ តុលាការគួរតែបកស្រាយនូវមធ្យោបាយស្វែងរកថវិកាផ្សេងៗដែលអាចធ្វើទៅបាន ទាំងនៅក្នុងក្របខណ្ឌរបស់តុលាការ ក៏ដូចជា នៅក្រៅតុលាការ ព្រមទាំងអំពីលទ្ធភាពទទួលបាននូវប្រភពថវិកា ទោះបីជាតិចតួចបំផុតក្តី ពីថ្នាក់ប្រជាពលរដ្ឋកម្ពុជានៅតាមសហគមន៍ រហូតដល់ថ្នាក់រាជរដ្ឋាភិបាល និងអ្នកជំនួញ និងប្រភពថវិកាឯកជន ដទៃទៀតផងដែរ ។

ឆ្នាំ២០១០ ខាងមុខ គឺជាឆ្នាំដ៏មានសារៈសំខាន់សំរាប់ឱ្យអង្គជំនុំជម្រះវិសាមញ្ញធ្វើការឆ្លុះបញ្ចាំងនូវការងារបច្ចុប្បន្នភាព ក៏ដូចជាត្រៀមជាស្រេចចំពោះបញ្ហាប្រឈមមុខនានាដែលអាចកើតឡើងនាពេលខាងមុខទៀត ។ ចៅក្រមទាំងអស់ គួរតែប្រើប្រាស់នូវពេលវេលា នៅបន្ទាប់ពីការបញ្ចប់សាលក្រមនៃសំណុំរឿង ០០១ ដើម្បីធ្វើការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ក៏ដូចជា អ្នកជំនាញការ ព្រមទាំងអ្នកផ្សេងទៀត អំពីទិសដៅអនាគត ស្តីពីការគិតគូរអំពីបញ្ហាសំណងដែលមានលក្ខណៈអាចបត់បែនបាន និងមានន័យពេញលេញ ។

*គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)- គឺជាសម្ព័ន្ធ អង្គការ-សមាគមមិនមែនរដ្ឋាភិបាលដែលមានសមាជិកចំនួន ២១ ដែលធ្វើការនៅក្នុងប្រទេសកម្ពុជាទៅលើវិស័យ សិទ្ធិមនុស្ស ច្បាប់ និងលទ្ធិប្រជាធិបតេយ្យ ។ សំរាប់ព័ត៌មានលំអិតសូមមើលគេហទំព័រ:* www.chrac.org

*អង្គការ Redresss គឺជាអង្គការសិទ្ធិមនុស្សអន្តរជាតិដែលមានមូលដ្ឋាននៅក្នុងប្រទេសអង់គ្លេស ដែលធ្វើការជួយគាំទ្រជនរងគ្រោះដោយអំពើទារុណកម្ម និងឧក្រិដ្ឋកម្មពាក់ព័ន្ធផ្សេងៗទៀត ដើម្បីស្វែងរកយុត្តិធម៌ជូនពួកគេ ។ សំរាប់ព័ត៌មានលំអិតសូមមើល គេហទំព័រ:* www.redress.org